ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ

# (កម្មករជាប់កិច្ចសន្យា កម្មករផ្គត់ផ្គង់បឋម និងកម្មករពីសហគមន៍)

## គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី ៣

(LASED III)

រៀបចំដោយ÷ ក្រុមការងារផ្នែកគាំពារបរិស្ថាន និងសង្គម

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

# មាតិកា


១. គោលបំណង.......................................................................................................... 1

២. គោលដៅ............................................................................................................... 1

៣. គោលការណ៍នៃយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករក្នុងគម្រោង LASED III (កម្មករជាប់កិច្ចសន្យា កម្មករផ្គត់ផ្គង់បឋម និងកម្មករពីសហគមន៍) ........................................................... 2

៤. ការរៀបចំស្ថាប័នសម្រាប់យន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករក្នុងគម្រោង LASED III........... 3

៥. ភារកិច្ចរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ.................................................... 6

៦. ដំណើការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ (លើកលែងកម្មករធ្វើការក្នុងសហគន៍/សហគមន៍ដែលបានចូលរួមពលកម្មជាមួយគម្រោងដោយស្ម័គ្រចិត្ត) ........................................................... 7

## ១. គោលបំណង

- យន្តការដោះស្រាយបណ្តឹងតវ៉ានេះ (ហៅកាត់ថា GRM-W) គឺសម្រាប់បុគ្គលគ្រប់រូបដែលជាកម្មករធ្វើការក្នុងគម្រោង LASED III ដែលគិតថាខ្លួនទទួលនូវការកេងប្រវ័ញ្ច រំលោភបំពានលើសិទ្ធិ សុវត្ថិភាព និងសុខភាព សិទ្ធិការងារ (ការប្រព្រឹត្តដោយយុត្តិធម៌ ការមិនរើសអើង និងឱកាសស្មើគ្នា) ត្រូវបានរំលោភបំពាន។ បុគ្គលគ្រប់រូបមានសិទ្ធិដោយគ្មានការរឹតត្បិតក្នុងការប្រើប្រាស់យន្តការនេះ ដែលអនុវត្តចំពោះតែគម្រោង LASED III ប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាព ដើម្បីទទួលបាននូវដំណោះស្រាយសមស្រប។
- បណ្តឹងតវ៉ារបស់កម្មករដែលធ្វើការក្នុងគម្រោង LASED III គឺត្រូវដោះស្រាយភ្លាមៗនូវការព្រួយបារម្ភនៅកន្លែងធ្វើការ ដោយប្រើប្រាស់ដំណើរការដោះស្រាយបណ្តឹងតវ៉ាងាយៗ និងមានតម្លាភាព រួមទាំងការផ្តល់ព័ត៌មានត្រឡប់ដល់អ្នកពាក់ព័ន្ធទាន់ពេលវេលា ដោយប្រើភាសាដែលពួកគេងាយយល់ មានលក្ខណៈឯករាជ្យ និងសត្យានុម័តដោយអនុលោមតាមក្របខណ្ឌច្បាប់ បទប្បញ្ញត្តិ ដែលមានស្រាប់របស់ប្រទេសកម្ពុជា ដូចជាច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧, សៀវភៅណែនាំការអនុវត្តគម្រោង (PIM), និងបទដ្ឋានបរិស្ថាន និងសង្គម លើកទី២ (ESS 2), នីតិវិធីស្តីពីលក្ខខណ្ឌពលកម្ម និងការងារ, ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម(ESMF), ផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP) និងនីតិវិធីគ្រប់គ្រង់លក្ខខណ្ឌពលកម្ម និងការងារ (LWCP ) ។

## ២. គោលដៅ

- បុគ្គលគ្រប់រូបដែលជាកម្មករធ្វើការងារក្នុងគម្រោង LASED III ដែលរងនូវការកេងប្រវ័ញ្ច រំលោភបំពានលើសិទ្ធិ សុវត្ថិភាព និងសុខភាព អាចទទួលបានដំណើរការយុត្តិធម៌ដូចបានពិពណ៌នានៅក្នុងយន្តការបណ្តឹងតវ៉ារបស់កម្មករនេះ។
- បុគ្គលគ្រប់រូបដែលជាកម្មករធ្វើការងារក្នុងគម្រោងLASED III នឹងដឹងច្បាស់អំពីយន្តការបណ្តឹងតវ៉ា និងមានសិទ្ធិក្នុងការដាក់បណ្តឹងតវ៉ា (រួមទាំងព័ត៌មានត្រលប់) និងដើម្បីដាក់ពាក្យបណ្តឹងប្រឆាំងនឹងការអនុវត្តសកម្មភាពមិនត្រឹមត្រូវរបស់អ្នកដឹកនាំគ្រប់គ្រងអនុវត្តគម្រោង អ្នកម៉ៅការ ផ្តល់សេវា និងអ្នកផ្គត់ផ្គង់។
- អ្នកពាក់ព័ន្ធទាំងអស់ នឹងដឹងច្បាស់អំពីយន្តការនេះ ដូចជា÷
    - របៀបដាក់ពាក្យបណ្តឹង
    - នីតិវិធីបណ្តឹងតវ៉ា
    - រយៈពេលនៃការចេញសេចក្តីសម្រេច។

## ៣. គោលការណ៍នៃយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករក្នុងគម្រោង LASED III (កម្មករជាប់កិច្ចសន្យា កម្មករផ្គត់ផ្គង់បឋម និងកម្មករពីសហគមន៍)

- **ភាពបើកចំហរ និងតម្លាភាព÷** គម្រោងកត់ត្រារាល់ព័ត៌មានឆ្លើយតប ពាក្យបណ្តឹង ដែលបានដាក់រួមទាំងលទ្ធផល ខ្លឹមសារ និងពេលវេលាដែលចំណាយលើការពិចារណា និងដោះស្រាយបណ្តឹងតវ៉ា។ ខ្លឹមសារសង្ខេបនៃកំណត់ត្រា នឹងត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់។ គម្រោងចាត់ទុកព័ត៌មានឆ្លើយតប ពាក្យបណ្តឹងដែលបានទទួលទាំងអស់ជាឱកាសសម្រាប់កែលម្អគម្រោង។

- **ភាពត្រឹមត្រូវ÷** រាល់បណ្តឹងតវ៉ាទាំងអស់ នឹងត្រូវបានដាក់ដោយឆន្ទៈផ្ទាល់ខ្លួន ហើយត្រូវបានវាយតម្លៃដោយផ្អែកលើអង្គសេចក្តីរបស់បណ្តឹង ដោយមិនគិតពីអត្តសញ្ញាណឬឋានៈរបស់អ្នកប្តឹង។ ពាក្យបណ្តឹងនេះ នឹងត្រូវបានវាយតម្លៃដោយសត្យានុម័តមិនលម្អៀងដោយអនុលោមតាមច្បាប់ និងវិធានពាក់ព័ន្ធ និងគោលការណ៍ណែនាំប្រតិបត្តិការរបស់គម្រោង LASED III។ ក្នុងករណីដែលពាក់ព័ន្ធសុពលភាពនៃបណ្តឹង ការតវ៉ានឹងត្រូវបានវាយតម្លៃដោយផ្អែកលើបទប្បញ្ញត្តិប្រតិបត្តិ និងមិនបង្កគ្រោះថ្នាក់។
- **ភាពងាយស្រួលប្រើប្រាស់÷** គម្រោងមានគោលបំណងធានាថា កម្មករទទួលរងផលប៉ះពាល់ពីការធ្វើការក្នុងគម្រោងទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងៗអាចប្រើប្រាស់យន្តការដោះស្រាយបណ្តឹងតវ៉ាដោយមិនគិតថ្លៃ។ អ្នកប្តឹងអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ (លាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់) ឬតាមរយៈអ្នកសម្របសម្រួលអភិវឌ្ឍន៍សហគមន៍ ឬ អង្គការ ឬ ស្ថាប័នតំណាង។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ដែលមិនមែនជាអង្គការដៃគូ ក៏អាចដាក់ពាក្យបណ្តឹងជំនួសពួកគាត់បាន ប្រសិនបើមានការស្នើសុំដោយអ្នកប្តឹងម្នាក់ ឬ ច្រើននាក់ ដែលមានអារម្មណ៍ថាពួកគាត់ត្រូវបានរងផលប៉ះពាល់អវិជ្ជមានពីការធ្វើការងារជាមួយអ្នកម៉ៅការ អ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់ក្នុងគម្រោង។ ព័ត៌មានអំពីយន្តការនេះនឹងមានជាភាសាខ្មែរ ហើយនឹងត្រូវបានបង្ហោះនៅក្នុងគេហទំព័ររបស់គម្រោង ដោយផ្សព្វផ្សាយនៅក្នុងឯកសារគម្រោង ពិសេសឯកសារដែលផ្តោតលើប្រជាពលរដ្ឋមូលដ្ឋាន ដូចជាវិធានការផ្ទៃក្នុងរបស់ស្ថាប័នជនក្រីក្រ សៀវភៅណែនាំបច្ចេកទេស និងខិត្តប័ណ្ណជាដើម។ ព័ត៌មានអំពីបណ្តឹងតវ៉ារបស់កម្មករ ត្រូវបានផ្តល់ជូនផងដែរក្នុងកិច្ចប្រជុំនៅពេលចាប់ផ្តើមការងារជាមួយសហគមន៍ អ្នកទទួលផលដែលមានសក្តានុពលទាំងអស់។
- **ការឆ្លើយតប និងប្រសិទ្ធភាព÷** គម្រោងនឹងដំណើរការ និងឆ្លើយតបរាល់ព័ត៌មានត្រឡប់ ពាក្យបណ្តឹងឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ គម្រោងនឹងជូនដំណឹងពីការទទួលព័ត៌មានត្រឡប់ពាក្យបណ្តឹងក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ។ យន្តការនេះនឹងចំណាយពេលវេលារហូតដល់៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបណ្តឹងតវ៉ាត្រូវបានដាក់ជូនដំណើរការ ដោយទុកពេលវេលាសម្រាប់ការប្រមូលព័ត៌មាន

និងពិនិត្យភស្តុតាង (បើចំបាច់)។ យន្តការនេះអាចត្រូវការពេលវេលាបន្ថែមសម្រាប់ការចរចាជាមួយភាគីនៃបណ្តឹង ប៉ុន្តែដំណោះស្រាយនេះមិនលើស៤៥ នៃថ្ងៃធ្វើការឡើយ។

- **អនាមិកភាព និងការសម្ងាត់÷** បុគ្គលឬស្ថាប័នដែលដាក់ជូនព័ត៌មានពាក្យបណ្តឹង អាចស្នើសុំអនាមិកភាព ដែលក្នុងករណីនេះឈ្មោះរបស់គាត់នឹងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ការសម្ងាត់ ក៏នឹងត្រូវរក្សាផងដែរក្នុងអំឡុងពេលដែលគណៈកម្មការយន្តការដោះស្រាយបណ្តឹងតវ៉ាកំពុងពិចារណាករណីណាមួយ (ឧទាហរណ៍ ប្រភព និងបុគ្គលណាមួយ អ្នកម៉ៅការ ឬ អង្គភាពដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តខុសគួរតែត្រូវបានការពារ)។ ប្រសិនបើពួកគាត់ត្រូវបានរកឃើញថាបានប្រព្រឹត្តខុសបន្តិចបន្តួចដែលពួកគាត់ត្រូវបានចោទប្រកាន់នោះ ពួកគាត់នឹងត្រូវបានពន្យល់ពីការធ្វើខុសទទួលយកកំហុស និងអនុវត្តវិធានការសម្រាល។ ប៉ុន្តែចំពោះករណីឧក្រិដ្ឋកម្ម ឧទាហរណ៍ ការក្លែងបន្លំចោរកម្ម ដែលបំពានច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នឹងទាមទារឱ្យមានចំណាត់ការដោយតុលាការ។

## ៤. ការរៀបចំស្ថាប័នសម្រាប់យន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករក្នុងគម្រោង LASED III

- **គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ជាតិ ក្នុងគម្រោង LASED III មានទីតាំងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម÷**
  - នាយកគម្រោង — ប្រធាន

    **ឯកឧត្តម រ័ត្ន ហុក** លេខទូរស័ព្ទ 012 823 714 អ៊ីម៉ែល hokroth@gmail.com
  - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ទទួលបន្ទុកដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ — សមាជិក

    **ឯកឧត្តម ឃី កុសល** លេខទូរស័ព្ទ 081 839 345 អ៊ីម៉ែល kosalkhy@yahoo.com
  - មន្ត្រីបង្គោលទទួលបន្ទុកដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ (ក្រសួងដែនដី) — សមាជិក

    **លោក ឫទ្ធី រតនៈជ័យសិទ្ធ** លេខទូរស័ព្ទ ០១៧ ៩៨៨ ៣៣៣ អ៊ីម៉ែល rrcheysith@yahoo.com
  - អង្គការមិនមែនរដ្ឋាភិបាល (តំណាងឯករាជ្យ) — សមាជិក
  - ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម — លេខា

អ្នកប្តឹងក៏អាចដាក់បណ្តឹងតវ៉ា ឬ ទុកកង្វល់របស់កម្មករដែលទទួលរងផលប៉ះពាល់អវិជ្ជមាន តាមរយៈអ៊ីមែល LASEDIIIGRM@GMAIL.COM

- **គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត ក្នុងគម្រោង LASED III មានទីតាំងនៅសាលាខេត្ត ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។ គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម÷**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

អ្នកប្តឹងក៏អាចដាក់បណ្តឹងតវ៉ាឬទុកកង្វល់របស់កម្មករដែលទទួលរងផលប៉ះពាល់អវិជ្ជមាន តាមរយៈ អ៊ីមែល LASEDIIIGRM@GMAIL.COM

# យន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករក្នុងគម្រោង LASED III



## ៥. ភារកិច្ចរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ

- **តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ជាតិ រួមមាន៖**

  ក. ចងក្រងកត់ត្រាពាក្យបណ្តឹង និងព័ត៌មានត្រឡប់ទាំងអស់ និងលទ្ធផលដំណោះស្រាយ

  ខ. កសាងសមត្ថភាព និងផ្តល់ការគាំទ្រ ការណែនាំ រួមទាំងដំណើរការដោះស្រាយបណ្តឹងតវ៉ា ភ្នាក់ងារអនុវត្តគម្រោង អ្នកម៉ៅការ អ្នកផ្តល់សេវា អ្នកផ្គត់ផ្គង់ និងដៃគូទាំងអស់។

  គ. អន្តរាគមន៍ដោយផ្ទាល់ ដើម្បីជួយដោះស្រាយបណ្តឹងតវ៉ា ប្រសិនបើចាំបាច់ ហើយនៅពេលដែលតវ៉ាដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្ត។ នាយកគម្រោងត្រូវត្រួតពិនិត្យការអនុវត្តយន្តការដោះស្រាយបណ្តឹងតវ៉ា ដោយមានជំនួយពីទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមថ្នាក់ជាតិ។

  ឃ. ត្រួតពិនិត្យដំណើរការ ប្រសិនបើចាំបាច់ និងត្រូវផ្តល់អនុសាសន៍សម្រាប់ការគ្រប់គ្រងពាក្យបណ្តឹងនៅថ្នាក់ជាតិ។ ឧទាហរណ៍ ក្នុងករណីបណ្តឹងពាក់ព័ន្ធជាមួយផ្នែកកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលជាភ្នាក់ងារអនុវត្តគម្រោង ត្រូវចាត់តាំងជនបង្គោលទទួលបន្ទុកការងារដោះស្រាយបណ្តឹងតវ៉ាសម្រាប់កម្មករ។

  ង. តាមដាន និងត្រួតពិនិត្យការអនុវត្តរបស់ក្រុមការងារដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ ដើម្បីធានាថា ការអនុវត្តស្របតាមនីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ និងកិច្ចសន្យាលក្ខខណ្ឌការងាររវាងគម្រោង និងអ្នកម៉ៅការ ឬ អ្នកផ្តល់សេវា ឬ អ្នកផ្គត់ផ្គង់។

  ច. រៀបចំរបាយការណ៍តាមការកំណត់អំពីសកម្មភាពនៃការគ្រប់គ្រងពាក្យបណ្តឹង រួមមាន៖ ១)ចំនួន និងប្រភេទនៃពាក្យបណ្តឹង ២)ព័ត៌មាននៃដំណោះស្រាយពាក្យបណ្តឹង (ចំនួនដែលបានដោះស្រាយ របៀបដោះស្រាយ និងពាក្យបណ្តឹងមិនទាន់ដោះស្រាយ) ៣)ណែនាំពីវិធានការពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ា និងទំហំនៃដំណោះស្រាយបណ្តឹងដល់គណៈកម្មការគ្រប់គ្រងគម្រោង។ របាយការណ៍ជូនធនាគារពិភពលោកប្រចាំឆមាស ស្តីពីបណ្តឹងតវ៉ារបស់កម្មករ និងទិន្នន័យយេនឌ័រ (ស្រី ប្រុស) ព្រមទាំងរបៀបដោះស្រាយ។

- **តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាកម្មករថ្នាក់ខេត្ត រួមមាន៖**

  ក. កត់ត្រាបណ្តឹងតវ៉ាក្នុងទម្រង់ស្តង់ដារ (ឧបសម្ព័ន្ធ១ក) និងចម្លងចូលក្នុងប្រព័ន្ធគោលគ្រប់គ្រងដោយមន្ត្រីបង្គោលទទួលបន្ទុកយន្តការដោះស្រាយរបស់កម្មកររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជូនដំណឹង និងពន្យល់ពីសិទ្ធិរបស់អ្នកប្តឹង និងពិនិត្យជាបឋមអំពីពាក្យបណ្តឹង ថាតើពាក្យបណ្តឹងមានពាក់ព័ន្ធនឹងសិទ្ធិរបស់កម្មករ លក្ខខណ្ឌពលកម្ម និងការងារ កិច្ចសន្យាការងាររវាងគម្រោង និងអ្នកម៉ៅការ ឬ អ្នកផ្តល់សេវា ឬ អ្នកផ្គត់ផ្គង់ និងយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករដែរឬទេ? ក្នុងករណីពាក្យបណ្តឹងមិនពាក់ព័ន្ធនឹងគម្រោង LASED III (យន្តការដោះស្រាយប

ណ្ដឹងតវ៉ាកម្មករ) ត្រូវបញ្ជូនទៅស្ថាប័នផ្សេងទៀត។ ក្នុងករណីបែបនេះ អ្នកប្ដឹងនឹងត្រូវបានពន្យល់ពីហេតុផលនេះយ៉ាងខ្លី។

ខ. រៀបចំលិខិតបញ្ជាក់ទទួលពាក្យបណ្ដឹង/ព័ត៌មានត្រឡប់ និងជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីចំណាត់ការដែលត្រូវអនុវត្ត និងបញ្ជាក់អំពីសិទ្ធិអ្នកប្ដឹង។

គ. ដំណើរការស៊ើបអង្កេត និងរៀបចំរបាយការណ៍អង្គហេតុសម្រាប់គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករនៅថ្នាក់ខេត្ត។

ឃ. ក្រុមការងារគណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករនៅថ្នាក់ខេត្ត ត្រូវរៀបចំកិច្ចប្រជុំពិនិត្យអង្គហេតុ សាកសួរអ្នកប្ដឹង អ្នកពាក់ព័ន្ធ និងសម្រេចលើចំណាត់ការ រួមមាន៖ ១). មិនចាត់ការ ២). ចាត់ការដើម្បីដោះស្រាយបណ្ដឹង ៣). និងបញ្ជូនសំណុំឯកសារនេះឱ្យមន្ត្រីបង្គោលថ្នាក់ជាតិ ក្នុងករណីមិនអាចដោះស្រាយបាន។

ង. រៀបចំលិខិតជូនដំណឹងទៅអ្នកប្ដឹង (រក្សាច្បាប់ចម្លង)។ រាល់បណ្ដឹងតវ៉ាត្រូវរក្សាការសម្ងាត់។

ច. ការចាត់វិធានការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករ។ ការដោះស្រាយបណ្ដឹងតវ៉ាត្រូវផ្អែកទៅលើកិច្ចសន្យារវាងគម្រោង និងអ្នកម៉ៅការ /អ្នកផ្ដល់សេវា/អ្នកផ្គត់ផ្គង់ទំនិញ និងនីតិវិធីដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករ បទដ្ឋាន និងសង្គមទី២ (ESS2) នីតិវិធីលក្ខខណ្ឌពលកម្ម និងការងារ (LWCP) និងច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧។

ឆ. កត់ត្រាលទ្ធផលក្នុងសៀវភៅដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករ និងរៀបចំរបាយការណ៍ដោយបញ្ជូនគណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករទៅថ្នាក់ជាតិតាមការកំណត់។

## ៦. ដំណើការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករ (លើកលែងកម្មករធ្វើការក្នុងសហគន៍/សហគមន៍ដែលបានចូលរួមពលកម្មជាមួយគម្រោងដោយស្ម័គ្រចិត្ត)

- បុគ្គលគ្រប់រូបដែលជាកម្មករឬតំណាង ដែលគិតថាទទួលរងផលប៉ះពាល់អវិជ្ជមាននូវការកេងប្រវ័ញ្ច រំលោភបំពានលើសិទ្ធិ សុវត្ថិភាព និងសុខភាព សិទ្ធិការងារ (ការប្រព្រឹត្តដោយយុត្តិធម៌ ការមិនរើសអើង និងឱកាសស្មើគ្នា) ត្រូវបានរំលោភបំពានដោយអ្នកម៉ៅការ/អ្នកផ្ដល់សេវា/អ្នកផ្គត់ផ្គង់ នៅក្នុងគម្រោង LASED III អាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ *(តាមអ៊ីមែល ទូរស័ព្ទ ឬ គណនីបណ្ដាញសង្គមរបស់គម្រោង)* ទៅកាន់បុគ្គលិក ភ្នាក់ងារអនុវត្តគម្រោង ឬ ស្ថាប័នដៃគូ (ឧបសម្ព័ន្ធ១ក) ឬ អាចបញ្ជូនបណ្ដឹងតវ៉ាតាមរយៈអ៊ីមែល៖ lasediiigrm@gmail.com ។
- ការទទួលពាក្យបណ្ដឹងបឋម គឺគណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត។ ទោះជាយ៉ាងណាក៏ដោយភាគីដែលទទួលរងនូវការកេងប្រវ័ញ្ច រំលោភបំពានលើសិទ្ធិ សុវត្ថិភាព និងសុខភាព

អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ជាតិ ឬ ទៅកាន់បុគ្គលិកនៃទីភ្នាក់ងារអនុវត្ត ឬ អង្គការដៃគូដែលគាំទ្រការអនុវត្ត។

- បុគ្គលដែលទទួលបានពាក្យបណ្តឹង ដោយមានជំនួយគាំទ្រពីមន្ត្រីបង្គោលទទួលបន្ទុកយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ ត្រូវរៀបចំឯកសារ និងបញ្ជូនពាក្យបណ្តឹងតវ៉ាទៅគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ា លេខាធិការរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្តនឹងចាត់វិធានការដូចខាងក្រោម÷
    - បញ្ចូលព័ត៌មានលម្អិតទៅក្នុងកំណត់ត្រាពាក្យបណ្តឹង (ឧបសម្ព័ន្ធ២ក)
    - កត់ត្រាពាក្យបណ្តឹងនៅក្នុងសៀវភៅបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត ជូនដំណឹងទៅប្រធានគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត និងរួចចម្លងចូលក្នុងសៀវភៅបណ្តឹងតវ៉ារបស់កម្មករថ្នាក់ជាតិ។
    - ពាក្យបណ្តឹងដែលមិនពាក់ព័ន្ធនឹងគម្រោងត្រូវបញ្ជូនទៅស្ថាប័ន ផ្សេង និងមានការពន្យល់ខ្លីទៅដល់អ្នកដាក់ពាក្យបណ្តឹង។
    - បន្ទាប់ពីទទួលពាក្យបណ្តឹង ចាំបាច់ត្រូវរៀបចំលិខិត ដែលមានបញ្ជាក់ដូចខាងក្រោម÷
        ក. បញ្ជាក់ថាបានទទួលពាក្យបណ្តឹង និងឆ្លើយតបទៅដើមបណ្តឹងវិញក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការងារ
        ខ. ជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីដំណើរការសកម្មភាពដែលត្រូវអនុវត្ត
        គ. ការបញ្ជាក់ពីសិទ្ធិរបស់អ្នកប្តឹង។
- **នីតិវិធីដោះស្រាយ រួមមាន÷**
    - ការពិនិត្យ និងកត់ត្រាបឋមលើទម្រង់នៃពាក្យបណ្តឹង ពន្យល់សិទ្ធិអ្នកប្តឹង ចម្លងចូលក្នុងសៀវភៅបណ្តឹង។ លេខាធិការរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត ត្រូវពិនិត្យ ថាតើបណ្តឹងពាក់ព័ន្ធទៅនឹងសិទ្ធិកម្មករក្នុងបរិបទគម្រោង LASED III ដែរឬទេ? រួចរៀបចំរបាយការណ៍ជូនដំណឹងដល់ប្រធានគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត។ ក្នុងករណីដែលពាក្យបណ្តឹង “មិនពាក់ព័ន្ធ ឬ ពាក់ព័ន្ធ” ទៅនឹងសិទ្ធិកម្មករក្នុងបរិបទគម្រោង LASED III គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្តនឹងចេញលិខិតឆ្លើយតបក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ។
    - ពាក្យបណ្តឹងត្រូវស៊ើបអង្កេតដោយមន្ត្រីបង្គោលទទួលបន្ទុកយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ និងទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមថ្នាក់ខេត្ត។ ការស៊ើបអង្កេត រួមមានការសម្ភាសន៍អ្នកប្តឹង បុគ្គលិកគម្រោង អ្នកម៉ៅការ អ្នកផ្តល់សេវា អ្នកផ្គត់ផ្គង់ និងអាជ្ញាធរមូលដ្ឋាន និងមនុស្សសំខាន់ៗនៅក្នុងទីតាំងអនុវត្ត។ បុគ្គលិកគម្រោងត្រូវសហការជាមួយក្រុមស៊ើបអង្កេត និងផ្តល់ឯកសារពាក់ព័ន្ធប្រសិនបើចាំបាច់។

- ប្រសិនបើអ្នកប្តឹងស្នើសុំមិនបញ្ចេញឈ្មោះ ក្រុមស៊ើបអង្កេតមិនត្រូវបង្ហាញអត្តសញ្ញាណរបស់អ្នកប្តឹងឡើយ។ ករណីខ្លះ ពាក្យបណ្តឹងមិនអាចស៊ើបអង្កេតបានទេ នៅពេលដែលអត្តសញ្ញាណរបស់អ្នកប្តឹងមិនត្រូវបានបង្ហាញដល់គណៈកម្មការ។ ក្នុងករណីនេះ គណៈកម្មការនៅតែមានបំណងដោះស្រាយបណ្តឹងតវ៉ាតាមលទ្ធភាពដែលអាចធ្វើទៅបានដោយផ្អែកលើព័ត៌មានដែលបានផ្តល់។ ក្រុមស៊ើបអង្កេតត្រូវបញ្ចប់ការស៊ើបអង្កេត និងរៀបចំបញ្ជូនរបាយការណ៍អង្គហេតុទៅគណៈកម្មការ។
- ក្រុមការងារស៊ើបអង្កេតមិនមានសិទ្ធិផ្តល់អនុសាសន៍ ប៉ុន្តែត្រូវធ្វើការរាយការណ៍ពីអង្គហេតុ។
- បន្ទាប់ពីទទួលបានការរាយការណ៍ស្តីពីអង្គហេតុពីក្រុមការងារស៊ើបអង្កេត គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្តនឹងរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យរបាយការណ៍ និងសម្រេចលើចំណាត់ការដូចខាងក្រោម÷

    ក. មិនចាត់ការ (ដោយចេញលិខិតពន្យល់អ្នកប្តឹង)

    ខ. ចាត់ការដើម្បីដោះស្រាយបណ្តឹង។ ជូនដំណឹងទៅនិយោជក (អ្នកម៉ៅការ អ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់) ពីបណ្តឹងតវ៉ា និងអញ្ជើញឱ្យនិយោជកចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យមើលអង្គហេតុបណ្តឹង ក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីការជូនដំណឹងបឋមអំពីបណ្តឹង។ ប្រសិនអ្នកប្តឹងមិនពេញចិត្តនឹងដំណោះស្រាយ អ្នកប្តឹងអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ជាតិ។

    គ. ក្នុងករណីគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្តមិនអាចដោះស្រាយបាន ពាក្យបណ្តឹងនឹងត្រូវបញ្ជូនទៅគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ជាតិ។ ករណីនេះ អ្នកប្តឹងត្រូវបានជូនដំណឹងពីចំណាត់បន្ត។ ប្រសិនគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ជាតិនៅតែមិនអាចដោះស្រាយបាន អ្នកប្តឹងអាចបញ្ជូនពាក្យបណ្តឹងទៅគណៈកម្មការដឹកនាំគម្រោង LASED III ដើម្បីជួយដោះស្រាយបន្ត។ ការចំណាយនានា (ឧ. សាហ៊ុយធ្វើដំណើរ ស្នាក់នៅ និងអាហារជាបន្ទុករបស់គម្រោង)។ លិខិតជូនដំណឹងពីដំណោះស្រាយ ឬ សេចក្តីសម្រេចដែលបានស្នើឡើង ត្រូវផ្ញើរជូនអ្នកប្តឹងនៅថ្ងៃបន្ទាប់ពីនីតិវិធីត្រូវបានបិទបញ្ចប់ ។

    ឃ. អ្នកប្តឹងអាចបញ្ជូនពាក្យបណ្តឹងទៅតុលាការ ប្រសិនបើ អ្នកប្តឹងមិនទទួលយកសេចក្តីសម្រេចរបស់គណៈកម្មការដឹកនាំគម្រោង LASED III។

- នៅគ្រប់ដំណាក់កាល និយោជកអាចស្នើសុំផ្សះផ្សាបណ្តឹងតវ៉ាបាន ដោយភាគីអ្នកប្តឹងគ្រាន់តែធ្វើការជូនដំណឹងទៅមន្ត្រីបង្គោលពីបណ្តឹងតវ៉ា។ ប្រសិនចាំបាច់ដំណើរការនេះ គួរមានអ្នកចូលរួមដឹងឮ ពីអាជ្ញាធរភូមិ ឃុំសាមី។

- កត់ត្រាលទ្ធផលបណ្តឹងតវ៉ារបស់កម្មករ និងបូកសរុបផ្ញើជូនថ្នាក់ជាតិ។ រាល់ឯកសារដែលពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងតវ៉ា មន្ត្រីបង្គោលទទួលបន្ទុកយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករត្រូវរក្សាការសម្ងាត់ រហូតទាល់តែបញ្ចប់នីតិវិធីបណ្តឹងតវ៉ា។ បន្ទាប់មក សំណុំឯកសារនោះនឹងត្រូវបានបញ្ជូនឱ្យមន្ត្រីបង្គោលថ្នាក់ជាតិទទួលបន្ទុកយន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មកររក្សាទុក។
- គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករ ត្រូវធ្វើការបញ្ចប់ដោះស្រាយពាក្យបណ្តឹងឱ្យបានឆាប់រហ័ស និងមិនលើសពីរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យបណ្តឹង។ ប្រសិនបើមិនអាចដោះស្រាយបានក្នុងអំឡុងពេលនេះ គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាគួរពិចារណាពន្យារពេលមិនលើស ១៥ថ្ងៃនៃថ្ងៃធ្វើការ និងជូនដំណឹងទៅអ្នកប្តឹងពីមូលហេតុនៃការពន្យារពេល។

សមាជិកគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករទាំងអស់ត្រូវបានបណ្តុះបណ្តាលពីនីតិវិធីអនុវត្តយន្តការដោះស្រាយបណ្តឹងតវ៉ា ដូចជា÷

- សិទ្ធិរបស់ភាគីពាក់ព័ន្ធក្នុងការដាក់ពាក្យបណ្តឹងតវ៉ា នីតិវិធី ដំណើរការ និងរក្សាការសម្ងាត់ (អាណាមិកភាព)
- ការកត់ត្រាបណ្តឹងតវ៉ាក្នុងទម្រង់ស្តង់ដា (ឧបសម្ពន្ធ ១ក) និងបញ្ជូនបែបបទបណ្តឹងតវ៉ា ឬ ភស្តុតាងឯកសារផ្សេងទៀតទៅគណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត។

# គំនូសបំព្រួញបណ្តឹងតវ៉ារបស់កម្មករ



**ឧបសម្ព័ន្ធ ១ក៖ ទម្រង់បណ្តឹងតវ៉ា**

## គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ (LASED III)

## (បណ្តឹងតវ៉ាសម្រាប់កម្មករជាប់កិច្ចសន្យា កម្មករផ្គត់ផ្គង់បឋម និងកម្មករពីសហគមន៍)

**កំណត់សំគាល់៖** មន្ត្រីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី៣ (LASED III) ដែលទទួលបានដំណឹងពីបណ្តឹងតវ៉ា ត្រូវកត់ក្នុងទម្រង់នេះភ្លាម និងឱ្យបានឆាប់តាមតែអាចធ្វើទៅបាន៖

ឈ្មោះអ្នកប្តឹង៖.......................................................ភេទ..............................អាយុ............................

ជនជាតិ៖............................ភូមិ៖.......................................ឃុំ៖......................................................

ស្រុក៖.....................................................................ខេត្ត៖..............................................................

ព័ត៌មានលម្អិតរបស់អ្នកប្តឹង (ទូរស័ព្ទ អ៊ីមែល)៖..................................................................................

តើអ្នកប្តឹងស្នើសុំមិនបញ្ចេញឈ្មោះដែរ ឬទេ? បាទ ☐ ទេ ☐

កាលបរិច្ឆេទ ម៉ោង នៃការទទួលពាក្យបណ្តឹង៖.................................................................................

វិធីសាស្ត្រដាក់បណ្តឹងតវ៉ា តាមរយៈ៖

- ទូរស័ព្ទលេខ៖

  .........................................................................................................................

- ដោយផ្ទាល់មាត់៖..........................................................................................................
- លាយលក្ខណ៍អក្សរ៖

  ....................................................................................................................

- អ៊ីមែល៖.......................................................................................................................
- ផ្សេងៗ៖.......................................................................................................................

បណ្តឹងតវ៉ាកត់ត្រាដោយឈ្មោះ៖...................................................តួនាទី៖................................................

ពិពណ៌នាអំពីបណ្តឹងតវ៉ាឱ្យបានពេញលេញតាមតែអាចធ្វើទៅបាន ក្នុងផ្នែកជម្លោះកិច្ចសន្យាខាងក្រោម៖

☐សុខភាព/អនាម័យ ☐ សុវត្ថិភាពការងារ ☐ ការរើសអើង និងភាពអយុត្តិធម៌

☐ ការងារដោយបង្ខំ និងពលកម្មកុមារ ☐ អំពើហិង្សាផ្សេងៗ ☐ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម

☐ ការតវ៉ា/សហជីព ☐ ផ្សេងៗ..........................................................................................

..........................................................................................................................................

តើអ្នកប្តឹង (កម្មករ) បានជូនដំណឹងអំពីសិទ្ធិរបស់គាត់ដែរ ឬទេ? ចាស/បាទ ☐ ទេ ☐

តើអ្នកប្តឹង (កម្មករ) បានជូនដំណឹងអំពីដំណើរការ ជំហានដោះស្រាយបន្ទាប់ និងរយៈពេលដែលត្រូវដោះស្រាយដែល ឬទេ? ចាស/បាទ ☐ ទេ ☐

**ឧបសម្ព័ន្ធ ២ក៖  កំណត់ត្រាបណ្តឹងតវ៉ា**

## គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ (LASED III)

## (បណ្តឹងតវ៉ាសម្រាប់កម្មករជាប់កិច្ចសន្យា កម្មករផ្គត់ផ្គង់បឋម និងកម្មករពីសហគមន៍)

ខេត្ត÷.............................................................

ស្រុក÷...........................................................

ឃុំ÷................................................................

| លេខទម្រង់ | ឈ្មោះអ្នកប្តឹង | បញ្ហាក្នុងពាក្យបណ្តឹង | កាលបរិច្ឆេទទទួលពាក្យ | ទទួលដោយ | ស្ថានភាព | ការឆ្លើយតប/ ដំណោះស្រាយ | |
|---|---|---|---|---|---|---|---|
| | | | | | | លទ្ធផល | កាលបរិច្ឆេទ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## ឧបសម្ព័ន្ធ ៣ក÷ គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត

គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករថ្នាក់ខេត្ត មានទីតាំងនៅសាលាខេត្ត ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត រួមមាន÷

### គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តរតនគិរី

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

### គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តមណ្ឌលគិរី

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

### គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តក្រចេះ

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

### គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តព្រះវិហារ

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល(ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តកំពង់ធំ**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល(ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តស្ទឹងត្រែង**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល(ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករខេត្តត្បូងឃ្មុំ**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា

- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករខេត្តបាត់ដំបង**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករខេត្តកំពង់ឆ្នាំង**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករខេត្តបន្ទាយមានជ័យ**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល (ភូមិគោលដៅ) សមាជិក

**គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករខេត្តឧត្ដរមានជ័យ**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
- អភិបាលស្រុក សមាជិក

- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី — សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម — ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល(ភូមិគោលដៅ) — សមាជិក

**គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករខេត្តសៀមរាប**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត — ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត — សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា — សមាជិក
- អភិបាលស្រុក — សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី — សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម — ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល(ភូមិគោលដៅ) — សមាជិក

**គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ារបស់កម្មករខេត្តកំពង់ស្ពឺ**

- ប្រធានសម្របសម្រួលគម្រោង ឬ ប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត — ប្រធាន
- ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្ត — សមាជិក
- មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា — សមាជិក
- អភិបាលស្រុក — សមាជិក
- ក្រុមប្រឹក្សាឃុំ សង្កាត់សាមី — សមាជិក
- ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម — ជាលេខា
- អង្គការមិនមែនរដ្ឋាភិបាល(ភូមិគោលដៅ) — សមាជិក